01628588

D381/15

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ៖ | ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ចៅ.ស (អ.ប.ជ ៦១) |
| ភាគីដាក់ឯកសារ៖ | មេធាវីការពារក្តីរបស់ យឹម ទិត្យ |
| ដាក់ជូន៖ | អង្គបុរេជំនុំជម្រះ |
| ភាសាដើម៖ | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១៩ |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 08-Oct-2019, 08:00
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សម្ងាត់**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ចៅ.ស ឬ អង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

***ការឆ្លើយតបរបស់ យឹម ទិត្យ ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ចំពោះបណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ***

---

**<u>ដាក់ដោយ៖</u>**

**សហមេធាវី**

សូ មូស្សេនី
Suzana TOMANOVIĆ

**<u>ផ្ញើជូន៖</u>**

**ចៅក្រមអង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គីមសាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម BAIK Kang Jin
ចៅក្រម ហួត វុទ្ធី
ចៅក្រមបម្រុង ប៉ែន ពេជ្រសាលី
ចៅក្រមបម្រុង Steven J. BWANA

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង
លោកស្រី Brenda J. HOLLIS

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៤**

តាមរយៈសហមេធាវីការពារក្តីរបស់ខ្លួន (“មេធាវីការពារក្តី”) លោក យឹម ទិត្យ សូមដាក់*ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ចំពោះបណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ* (“ការឆ្លើយតប”) ស្រប តាមវិធាន ២១ នៃវិធានផ្ទៃក្នុង (“វិធានផ្ទៃក្នុង”) របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”)។ ការឆ្លើយតបនេះចាំបាច់ត្រូវធ្វើឡើងដោយហេតុថា៖ (ក)សហព្រះរាជអាជ្ញាអន្តរជាតិ (“ស.ព.អ”) បញ្ជាក់មិនត្រឹមត្រូវអំពីសំណើសុំរបស់លោក យឹម ទិត្យ (ខ)ស.ព.អ ស្នើឡើងដោយមិនសមស្របសុំឱ្យអង្គបុរេជំនុំជម្រះ (“អ.ប.ជ”) កែតម្រូវដំណោះស្រាយដែលស្នើសុំដោយលោក យឹម ទិត្យ (គ) ស.ព.អ លើកឡើងដោយមិនសមស្របអំពីសំណើសុំដែលពុំពាក់ព័ន្ធ។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៩ មេធាវីការពារក្តីបានដាក់ *សំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ចំពោះបណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ* (“សំណើសុំ”)[1]។

២. នៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៩ ស.ព.អ បានដាក់*ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ* (“ចម្លើយតប”)[2]។

## II. ការឆ្លើយតប

### ក. សហព្រះរាជអាជ្ញាអន្តរជាតិ (“ស.ព.អ”) បញ្ជាក់មិនត្រឹមត្រូវអំពីសំណើសុំរបស់លោក យឹម ទិត្យ

៣. ស.ព.អ លើកឡើងថា លោក យឹម ទិត្យ បានស្នើសុំ “ពន្យារពេលវេលាកំណត់ដើម្បីដាក់បណ្តឹង

[1] *សំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ*, ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៩, ឯកសារ D381/8។

[2] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ*, ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៩, ឯកសារ D381/13។

ឧទ្ធរណ៍របស់ យឹម ទិត្យ *ជាពីរភាសា*"[3]។ ខុសពីការអះអាងរបស់ ស.ព.អ មេធាវីការពារក្ដីបានស្នើសុំពន្យារពេលកំណត់ជាធរមាន ដោយពុំបានយោងលើការដាក់ជាពីរភាសានោះឡើយ។

៤. ទោះបីជា ស.ព.អ ទទួលបានប្រយោជន៍ដោយមានអ្នកបកប្រែនៅក្នុងការិយាល័យរបស់ខ្លួនក៏ដោយ[4] មេធាវីការពារក្ដីបានពឹងផ្អែកលើសេវារបស់អង្គភាពបកប្រែភាសា (អ.ប.ភ)។ ដូច្នេះ លទ្ធភាពរបស់មេធាវីការពារក្ដីនៅក្នុងការដាក់ឯកសារជាពីរភាសាត្រឹមកាលបរិច្ឆេទកំណត់ គឺអាស្រ័យលើលទ្ធភាពរបស់ អ.ប.ភ នៅមុនពេលដាក់ឯកសារ។ យោងតាមការអនុវត្តជាធរមាន ករណីនេះចាំបាច់ត្រូវវាយតម្លៃនៅដំណាក់កាលក្រោយ នៅពេលបញ្ចប់ការដាក់ទឡ្ហីករណ៍បណ្ដឹងឧទ្ធរណ៍ និងក្រោយពេលមានការពិគ្រោះយោបល់ជាមួយ អ.ប.ភ។ មេធាវីការពារក្ដីពុំមានលទ្ធភាពបញ្ជាក់ជាក់លាក់លើករណីនេះនៅក្នុងដំណាក់កាលនេះឡើយ ហើយវាមិនមែនអាស្រ័យលើ ស.ព.អ ជាអ្នកស្នើសុំឱ្យកំណត់ដូច្នេះ ក្នុងលក្ខណៈបែបនេះឡើយ។

**(ខ) ស.ព.អ ស្នើឡើងដោយមិនសមស្របសុំឱ្យអង្គបុរេជំនុំជម្រះ ("អ.ប.ជ") កែតម្រូវដំណោះស្រាយ ដែលស្នើសុំដោយលោក យឹម ទិត្យ**

៥. ស.ព.អ ស្នើសុំឱ្យ អ.ប.ជ កុំពិចារណាលើដំណោះស្រាយដែលស្នើសុំដោយលោក យឹម ទិត្យ នៅក្នុងសំណើសុំ ហើយតម្រូវឱ្យលោក យឹម ទិត្យ ដាក់ "បណ្ដឹងឧទ្ធរណ៍ចំនួនពីររបស់គាត់ ជាពីរឯកសារដាច់ដោយឡែកពីគ្នា"[5]។

៦. នៅពេលពិចារណាលើការអនុវត្តជាធរមាន និងយុត្តិសាស្ត្ររបស់តុលាការ វិធាន ៦៧(៥) ពុំបានចែងច្បាស់លាស់ ថាតើតុលាការអនុញ្ញាតឱ្យធ្វើបណ្ដឹងឧទ្ធរណ៍ចំនួនពីរប្រឆាំងនឹងដីកាដំណោះ

---

[3] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់បណ្ដឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ*, ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៩, ឯកសារ D381/13 កថាខណ្ឌ ១ (គូសបញ្ជាក់បន្ថែម)។

[4] *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ប្រឆាំងទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាភាសាអង់គ្លេសជាមុនសិន*, ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D382/14 កថាខណ្ឌ ៧។

[5] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់បណ្ដឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ*, ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០១៩, ឯកសារ D381/13 កថាខណ្ឌ ២។

ស្រាយតែមួយដែរឬទេ[6]។ម្យ៉ាងវិញទៀត យោងតាមការអនុវត្តនាពេលបច្ចុប្បន្ន សំណើសុំរបស់ ស.ព.អ ពុំសមស្របឡើយ។ ចម្លើយតបអាចលើកឡើងបញ្ហានានានៅក្នុងសំណើសុំ ឬ បណ្ដឹងឧទ្ធរណ៍ ដែលខ្លួនឆ្លើយតប។ ចម្លើយតបពុំអាចអនុញ្ញាតឲ្យភាគីឆ្លើយតបលើកបញ្ហាថ្មី ឬ កែតម្រូវសំណើសុំដើមនោះទេ។

៧. លើសពីនេះ សំណើសុំរបស់ ស.ព.អ ផ្អែកលើការសន្មតគ្មានមូលដ្ឋានថា "ដោយសារភាពខុសគ្នានៃដីកាដំណោះស្រាយទាំងនេះ" បណ្ដឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ ពុំមានលក្ខណៈច្បាស់លាស់[7]។ បណ្ដឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ លើកឡើងកម្មវត្ថុតែមួយនៅក្នុងដីកាដំណោះស្រាយទាំងពីរ ដែលចាំបាច់មានដំណោះស្រាយដូចគ្នា ហេតុដូច្នេះ ដូចបានស្នើសុំ គួរចាំបាច់មាន បណ្ដឹងឧទ្ធរណ៍តែមួយប៉ុណ្ណោះ[8]។

## (គ) ស.ព.អ លើកឡើងដោយមិនសមស្របអំពីសំណើសុំដែលពុំពាក់ព័ន្ធ

៨. ស.ព.អ ស្នើសុំថា អ.ប.ជ "ធ្វើសមកាលកម្មពីខ្សែបន្ទាត់ពេលវេលាចំពោះសារណាបណ្ដឹងឧទ្ធរណ៍របស់ភាគីនានា ដូចដែលធ្លាប់មាននៅក្នុងសំណុំរឿងពីមុនៗនោះដែរ"[9]។ យោងតាមការអនុវត្តជាធរមាន ចម្លើយតបពុំបើកលទ្ធភាពឲ្យភាគីឆ្លើយតបដាក់សំណើសុំរបស់ខ្លួនផ្ទាល់នោះទេ។

៩. ប្រសិនបើ ស.ព.អ មានបំណងដាក់សំណើសុំថ្មីពាក់ព័ន្ធនឹងពេលវេលាកំណត់ ក្របខ័ណ្ឌ អ.វ.ត.ក

---

[6] *សេចក្ដីសម្រេចលើសេចក្ដីសង្ខេបបឋមរបស់សហព្រះរាជអាជ្ញាទាក់ទិននឹងបណ្ដឹងឧទ្ធរណ៍ដាច់ដោយឡែករបស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយស្ដីពីការឃុំខ្លួនបណ្ដោះអាសន្ន និងយុត្តាធិការ,* ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ D427/1/11 កថាខណ្ឌ ៦, ៧។ *សេចក្ដីសម្រេចលើសំណើជាបន្ទាន់របស់ អៀង សារី សុំបង្កើនចំនួនទំព័រកំណត់ដើម្បីដាក់បណ្ដឹងឧទ្ធរណ៍លើបញ្ហាយុត្តាធិការដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ* ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/1/3 កថាខណ្ឌ ១០។

[7] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់បណ្ដឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ,* ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០១៩, ឯកសារ D381/13 កថាខណ្ឌ ២។

[8] *សេចក្ដីសម្រេចលើសេចក្ដីសង្ខេបបឋមរបស់សហព្រះរាជអាជ្ញាទាក់ទិននឹងបណ្ដឹងឧទ្ធរណ៍ដាច់ដោយឡែករបស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយស្ដីពីការឃុំខ្លួនបណ្ដោះអាសន្ន និងយុត្តាធិការ,* ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ D427/1/11 កថាខណ្ឌ ៧។

[9] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់បណ្ដឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ,* ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០១៩, ឯកសារ D381/13 កថាខណ្ឌ ៣។

អនុញ្ញាតឲ្យលោកស្រីធ្វើបាន ហើយនៅពេលនោះ មេធាវីការពារក្ដីក៏មានលទ្ធភាពដាក់ចម្លើយតប ចំពោះសំណើសុំបែបនេះ ក្នុងករណីចាំបាច់។

**អាស្រ័យហេតុនេះ** យោងតាមហេតុផលដូចបានលើកឡើងនៅក្នុងសំណើសុំនេះ មេធាវីការពារក្ដីសូមគោរពស្នើសុំអង្គបុរេជំនុំជម្រះ៖

**ច្រានចោល** ចម្លើយតបរបស់ ស.ព.អ ទៅនឹងសំណើសុំរបស់លោក យឹម ទិត្យ ដោយសារពុំមានភាពពាក់ព័ន្ធ។

**យល់ព្រមតាម** សំណើសុំ។

សូមអង្គបុរេជំនុំជម្រះមេត្តាទទួលយកការឆ្លើយតបនេះដោយក្ដីគោរព។

| ___________________ | _______________________ |
|---|---|
| សូ មូស្សេទ្ធី | Suzana TOMANOVIĆ |

សហមេធាវីការពារក្ដី លោក យឹម ទិត្យ

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១៩